00243320

D99/3/41

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០១/១៨-០៧-២០០៧-អវតក-កសចស (អបជ០២)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ម៉ែន ពេជ្ជសាលី
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ៣ ធ្នូ ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 03 / DEC / 2008
ម៉ោង (Time/Heure): 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

---

សាធារណៈ

**សេចក្តីសម្រេចលើពាក្យសុំការពិចារណាឡើងវិញចំពោះសេចក្តីសម្រេចស្តីពីការដាក់ពាក្យសុំនៅក្នុងសំណុំរឿង "ឌុច"**

---

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
ពេជ្រ សម្បត្តិ
Alex BATES

**ជនត្រូវចោទ**

កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANNONE

**សហមេធាវីការពារក្តី**

ការ សាវុត្ថ
François ROUX

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 03 / DEC / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

00243321

D99/3/41

០០១/១៨-០៧-២០០៧-អវតក-កសចស (អបជ០២)

១. **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "**អ.វ.ត.ក**" កត់សម្គាល់ឃើញថា នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ខ្លួនបានទទួល"ពាក្យសុំការពិចារណាឡើងវិញលើសេចក្តីសម្រេចស្តីពីការដាក់ពាក្យសុំរបស់ជនត្រូវចោទ **អៀង សារី** នៅក្នុងសំណុំរឿងប្រឆាំងនឹងជនត្រូវចោទ **កាំង ហ្កេកអ៊ាវ** ហៅ "**ឌុច**"" ។

២. នៅក្នុង"សេចក្តីសម្រេចស្តីពីការដាក់ពាក្យសុំរបស់ជនត្រូវចោទ អៀង សារី នៅក្នុងសំណុំ រឿងប្រឆាំងនឹងជនត្រូវចោទ **កាំង ហ្កេកអ៊ាវ** ហៅ "**ឌុច**"" ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៨, អង្គបុរេជំនុំជម្រះ ពិចារណាឃើញថា ជនត្រូវចោទ **អៀង សារី** មិនមានសិទ្ធិដាក់ពាក្យសុំនៅក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/កសចស(អបជ០២)ទេ ដោយយោងទៅ លើសេចក្តីសម្រេចពីមុនទាក់ទងនឹងសំណើរបស់សហមេធាវីការពារក្តី សុំដាក់សារណាលើការអនុវត្តន៍ទ្រឹស្តីនៃសហកម្មឧក្រិដ្ឋកម្មរួម។

៣. នៅក្នុង"សេចក្តីសម្រេចលើសំណើរបស់លោក **អៀង សារី** សុំដាក់សារណាលើការអនុវត្តទ្រឹស្តីនៃសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងបណ្តឹងឧទ្ធរណ៍ របស់សហព្រះរាជអាជ្ញាចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណី **កាំង ហ្កេកអ៊ាវ** ហៅ "**ឌុច**"" ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៨, អង្គបុរេជំនុំជម្រះ យល់ឃើញថា ជនត្រូវចោទ **អៀង សារី** មិនមានសិទ្ធិចូលអន្តរាគមន៍ នៅក្នុងរឿងក្តីប្រឆាំងនឹងជនត្រូវចោទ **ឌុច** ឡើយ ចំពោះបញ្ហានៃការអនុវត្តន៍ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម។

៤. នៅក្នុងសេចក្តីសម្រេចចេញថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៨, អង្គបុរេជំនុំជម្រះបានប្រកាសមិនទទួលយកពាក្យសុំ ដែលដាក់ជូនដោយសហមេធាវីការពារក្តីរបស់ជនត្រូវចោទ **អៀង សារី** ដើម្បីសុំដក *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* មួយរូប ដោយសារតែ ជនត្រូវចោទមិនមានផលប្រយោជន៍ខាងផ្លូវច្បាប់ ក្នុងការដាក់សេចក្តីសន្និដ្ឋាននៅក្នុងករណីប្រឆាំងចំពោះជនត្រូវចោទ **ឌុច** ។

៥. អង្គបុរេជំនុំជម្រះ កត់សម្គាល់ឃើញថា ក្នុងសេចក្តីសម្រេចលើការដាក់ពាក្យសុំ ខ្លួនមិនបានប្រកាសបដិសេធ ឬក៏ប្រកាសមិនទទួលយកពាក្យសុំនោះទេ។ អង្គបុរេជំនុំជម្រះ បានសម្រេចថា ពាក្យសុំមិនអាចត្រូវដាក់បន្ថែមទៅក្នុងសំណុំរឿង សម្រាប់ធ្វើសេចក្តីសម្រេចលើអង្គសេចក្តី ដោយផ្អែកលើមូលដ្ឋានថា ភាគីដាក់ពាក្យសុំនេះមិនមានផលប្រយោជន៍ខាងផ្លូវច្បាប់ ចំពោះការដាក់ពាក្យសុំបែបនោះឡើយ។

៦. អង្គបុរេជំនុំជម្រះ បានសម្រេចនៅក្នុងសេចក្តីសម្រេចលើកមុនថា អង្គបុរេជំនុំជម្រះ អាចពិចារណាឡើងវិញនូវការសម្រេចរបស់ខ្លួន ក្នុងករណីដែលកាលៈទេសៈមានការផ្លាស់ប្តូរ ដែលកាលៈទេសៈទាំងនោះអាចជាអង្គហេតុ ឬអំណះអំណាងថ្មី ឬក្នុងករណីមានការកើតឡើងនូវលទ្ធផលណាមួយដែលមិនអាចគិតទុកជាមុន ហើយនាំដល់ភាពអយុត្តិធម៌។[១]

៧. សហមេធាវីការពារក្តី មិនបានដាក់បន្ថែមអង្គហេតុថ្មី អំណះអំណាងថ្មី ឬការផ្លាស់ប្តូរនៃកាលៈទេសៈ ដែលអាចជម្រុញឱ្យអង្គបុរេជំនុំជម្រះធ្វើការពិចារណាឡើងវិញលើសេចក្តីសម្រេចស្តីពីការដាក់ពាក្យសុំនោះឡើយ។ ជាការពិត អំណះអំណាងរបស់សហមេធាវីការពារក្តី គឺផ្អែកលើមូលដ្ឋាននៃការមិនយល់ស្របលើសេចក្តីសម្រេចដើម ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៨ និងផលប្រយោជន៍ ក្នុងការបង្កើតឯកសារផ្លូវច្បាប់ស្តីពីសេចក្តីសន្និដ្ឋានរបស់ខ្លួន នៅក្នុងសំណុំរឿង។ នៅពេលលោក **អៀង សារី** មិនមែនជាភាគីនៅក្នុងសំណុំរឿង **ឌុច** មិនមានភាពអយុត្តិធម៌ណាមួយ កើតចេញពីការបដិសេធចំពោះការមិនអនុញ្ញាតឱ្យសហមេធាវីការពារក្តី **អៀង សារី** បន្តដាក់សារណាលើទម្រង់នៃការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម។

[១] សេចក្តីសម្រេច ធារី សេង

D99/3/41

០០១/១៨-០៧-២០០៧-អវតក-កសចស (អបជ០២)

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេច÷**

- បដិសេធចោលសំណើសុំពិចារណាឡើងវិញ។
- មិនទទួលយកការដាក់ឧបសម្ព័ន្ធ ឯកសារយោងសំអាងផ្លូវច្បាប់ និងបញ្ជីមូលដ្ឋានភ្ជាប់ជាមួយពាក្យសុំ។ ／

ភ្នំពេញ ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

ប្រាក់ គឹមសាន